KHMER

# របៀបទទួលបានកិច្ចបំរើរបស់ BETTER START

ដើម្បីទទួលបានកិច្ចបំរើរបស់ Better Start កូនក្មេងដែលត្រូវបានធ្វើរោគវិនិច្ឆ័យថាមានសិទ្ធិទទួលបានកិច្ចបំរើ ត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការចុះបញ្ជីស្របច្បាប់ទាំងអស់ ហើយត្រូវចុះបញ្ជីឲ្យបានមុនគេចូលអាយុ៦ឆ្នាំ។ គ្រួសារទាំងឡាយនឹងត្រូវរង់ចាំរហូតដល់កូនចូលអាយុ៧ឆ្នាំ ទើបគេមានលទ្ធភាពទទួលបានប្រាក់ឧបត្ថម្ភ។ ,

## ការវាយតម្លៃ និងការចុះបញ្ជីស្របច្បាប់

ដើម្បីចុះបញ្ជីស្របច្បាប់ជាមួយ Better Start ភាពមានសិទ្ធិទទួលបានកិច្ចបំរើរបស់កូនលោកអ្នកត្រូវការវាយតម្លៃ និងបញ្ជាក់ដោយកិច្ចបំរើចុះបញ្ជីស្របច្បាប់ និងផ្តល់ព័ត៌មាន (RIS)។

ការវាយតម្លៃនេះអាចធ្វើឡើងដោយទល់មុខគ្នា តាមទូរស័ព្ទ អ៊ីនធើណិត អ៊ីម៉េល ឬការតភ្ជាប់ដោយវីឌីអូ។ នៅពេលវាយតម្លៃនេះ ឪពុក ម្តាយ ឬអ្នកថៃទាំកូនក្មេងនឹងត្រូវការផ្តល់ឯកសារឲ្យទៅអ្នកណែនាំកិច្ចបំរើចុះបញ្ជីស្របច្បាប់ និងផ្តល់ព័ត៌មាន ដែលជាអ្នកនិយាយជាមួយលោកអ្នករហូតដល់ចប់ដំណើរការ។

ភាពមានសិទ្ធិទទួលបានរបស់លោកអ្នកនឹងត្រូវគេវាយតម្លៃ ហើយប្រសិនបើបានបញ្ជាក់យល់ព្រម កូនរបស់លោកអ្នកនឹងត្រូវបានចុះបញ្ជីសម្រាប់ Better Start យ៉ាងឆាប់តាមលទ្ធភាពធ្វើបាន។

## ការបញ្ជូន

ពេលណាទទួលបានការយល់ព្រមហើយនោះ លោកអ្នកនឹងទទួលសំបុត្របញ្ជាក់មួយច្បាប់អំពីការចុះបញ្ជីស្របច្បាប់របស់កូនលោកអ្នក ជាមួយ Better Start ។ អ្នកណែនាំ RIS របស់លោកអ្នកអាចជួយផ្តល់ជូនឲ្យលោកអ្នកនូវព័ត៌មានអំពីកិច្ចបំរើធ្វើអន្តរាគមន៍ទាន់ពេល សម្រាប់កូនលោកអ្នក។

ដើម្បីទាក់ទង និងចុះបញ្ជីសម្រាប់ Better Start សូមទូរស័ព្ទមកសមាគមអ្នកមើលថៃ ក្នុងរដ្ឋ ឬដែនដីរបស់លោកអ្នកតាមលេខ **1800 242 636** ។

ចំពោះព័ត៌មានបន្ថែម សូមបើកមើលវិបសាយ **www.betterstart.net.au**




**CARERS ACT**
ទូរស័ព្ទ (02) 6296 9900
betterstart@carersact.asn.au
www.carersact.asn.au

**CARERS NSW**
ទូរស័ព្ទ (02) 9280 4744
betterstart@carersnsw.asn.au
www.carersnsw.asn.au

**CARERS NT**
ទូរស័ព្ទ (08) 8944 4888
carersnt@carersnt.asn.au
www.carersnt.asn.au

**CARERS QLD**
ទូរស័ព្ទ (07) 3900 8100
betterstart@carersqld.asn.au
www.carersqld.asn.au

**CARERS SA**
ទូរស័ព្ទ (08) 8291 5600
betterstart@carers-sa.asn.au
www.carers-sa.asn.au

**CARERS TAS**
ទូរស័ព្ទ (03) 6231 5507
betterstart@carerstas.org
www.carerstas.org

**CARERS VIC**
ទូរស័ព្ទ 03 9396 9500
betterstart@carersvictoria.org.au
www.carersvictoria.org.au

**CARERS WA**
ទូរស័ព្ទ 08 9228 7400
betterstart@carerswa.asn.au
www.carerswa.asn.au

ព័ត៌មានសម្រាប់ទាក់ទងឯទៀត


Australian Government
Department of Families, Housing, Community Services and Indigenous Affairs

Carers AUSTRALIA

CRE8IVE 12532-0113


# Better Start សម្រាប់កុមារមានពិការភាព (Better Start)

## កិច្ចបំរើចុះបញ្ជីស្របច្បាប់ និងផ្តល់ព័ត៌មាន (RIS)

ស្វែងរកឲ្យបានដឹងថាតើលោកអ្នកអាចមានលទ្ធភាពទទួលប្រាក់ឧបត្ថម្ភបានដល់ទៅ $12,000 ឬទេ ពីការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់កិច្ចបំរើធ្វើអន្តរាគមន៍ទាន់ពេល និងការព្យាបាលសម្រាប់កុមារដែលមានសិទ្ធិទទួលបាន

BETTER START

ទូរស័ព្ទ **1800 242 636**
**www.betterstart.net.au**

# តើ Better Start ជាអ្វី?

Better Start គឺជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី ដែលឧបត្ថម្ភប្រាក់ដោយក្រសួងកិច្ចបំរើគ្រួសារ លំនៅដ្ឋាន សហគមន៍ និងកិច្ចការជនជាតិដើម (FaHCSIA)។

កិច្ចបំរើចុះបញ្ជីស្របច្បាប់ និងផ្តល់ព័ត៌មាន (RIS) ជួយឪពុកម្តាយ និងអ្នកមើលថែទាំងឡាយដោយផ្តល់ព័ត៌មានជូនគេអំពីការចុះឈ្មោះក្នុងបញ្ជីរបស់ Better Start និងជម្រើសនៃកិច្ចបំរើធ្វើអន្តរាគមន៍ទាន់ពេល។

RIS ត្រូវបានផ្តល់ជូនដោយបុគ្គលិកមានជំនាញនៅក្នុងសមាគមអ្នកមើលថែក្នុងរដ្ឋ និងដែនដីនីមួយៗ។

ភស្តុតាងបង្ហាញថា ការធ្វើអន្តរាគមន៍ទាន់ពេលដែលបានកំណត់គោលដៅសម្រាប់កុមារពិការដែលមានសិទ្ធិទទួលបាន ជួយរៀបចំគេឲ្យបានប្រសើរសម្រាប់ការផ្លាស់ប្តូរទៅសាលារៀន។

កុមារដែលបានចុះបញ្ជីជាមួយ Better Start អាចទទួលបានប្រាក់ឧបត្ថម្ភដល់ទៅ $12,000 (ច្រើនបំផុតដល់ទៅ $6,000 ក្នុងឆ្នាំសារពើព័ន្ធ) ដើម្បីបង់សម្រាប់កិច្ចបំរើធ្វើអន្តរាគមន៍ ផ្តល់ជូនដោយស្ថាប័នផ្តល់កិច្ចបំរើដែលបានចុះបញ្ជីស្របច្បាប់។

គ្រួសារទាំងឡាយដែលរស់នៅខាងក្រៅតំបន់ ឬទីឆ្ងាយដាច់ស្រយាលអាចមានសិទ្ធិទទួលបានប្រាក់ជំនួយសម្រាប់ផ្គត់ផ្គង់បន្ថែមតែម្តងគត់ ចំនួន $2,000។ ប្រាក់ជំនួយនេះនឹងជួយចំពោះការចំណាយបន្ថែមទាំងឡាយដូចជាការធ្វើដំណើរ និងការមកពិនិត្យដល់ផ្ទះ ទាក់ទិននឹងកិច្ចបំរើដែលទទួលបានជាដើម។

**ភាពមានសិទ្ធទទួលបានប្រាក់ជំនួយបន្ថែមនេះ ត្រូវបានវាយតម្លៃនៅពេលលោកអ្នកចុះបញ្ជីជាមួយ Better Start។**

**អំពីប្រាក់ឧបត្ថម្ភ**
ប្រាក់ឧបត្ថម្ភអាចប្រើដើម្បីបង់សម្រាប់កិច្ចបំរើធ្វើអន្តរាគមន៍ទាន់ពេល ផ្តល់ឲ្យដោយអ្នកវិជ្ជាជីវៈផ្នែកធ្វើអន្តរាគមន៍ទាន់ពេលមួយចំនួន ដែលជាសមាជិកគណៈវិនិច្ឆ័យនៃអ្នកផ្តល់កិច្ចបំរើធ្វើអន្តរាគមន៍ទាន់ពេលរបស់ Better Start ។

អ្នកវិជ្ជាជីវៈនៅក្នុងគណៈវិនិច្ឆ័យក៏ប៉ុន្តែពុំមែនមានកំណត់តែប៉ុណ្ណោះឡើយគឺ:

- អ្នកព្យាបាលជម្ងឺក្នុងការនិយាយស្តី និងបញ្ចេញសម្លេង
- អ្នកមានវិជ្ជាជីវៈផ្នែកសោតវិញ្ញាណ
- អ្នកព្យាបាលឲ្យមានសមត្ថភាពក្នុងការងារឡើងវិញ
- អ្នកព្យាបាលជម្ងឺដោយធ្វើចលនា
- អ្នកចិត្តសាស្ត្រ
- អ្នកឯកទេសព្យាបាលជម្ងឺភ្នែកស្រលេវ
- គ្រូបង្រៀនមនុស្សថ្លង់
- ពេទ្យពិនិត្យមើលភ្នែក



# តើនរណាមានសិទ្ធិទទួលបាន?

កុមារអាយុក្រោមប្រាំមួយឆ្នាំ ហើយត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានពិការភាពមួយនៃពិការភាពដូចតទៅនេះ ហើយសមស្របតាមកំរិតយ៉ាងតិចបំផុតដែលតម្រូវឲ្យមាន គេមានសិទ្ធិទទួលបានប្រាក់ឧបត្ថមរបស់ Better Start។

**កំរិតយ៉ាងតិចបំផុតនៃភាពមានសិទ្ធិទទួលបាននឹងត្រូវអនុវត្ត។** កំរិតយ៉ាងតិចបំផុតទាំងនេះត្រូវបានកំណត់ដោយ FaHCSIA ក្នុងការពិគ្រោះយោបល់ជាមួយ Expert Reference Group (ក្រុមអ្នកជំនាញយោង) ហើយត្រូវបានយល់ព្រមដោយលេខាធិការនៃរដ្ឋសភាផ្នែកពិការភាព និងអ្នកមើលថែ។

កុមារទាំងអស់ដែលបានធ្វើរោគវិនិច្ឆ័យបញ្ជាក់ថាមានពិការភាព ដូចបានរាយឈ្មោះខាងក្រោមនេះ មានសិទ្ធិទទួលបានកិច្ចបំរើពី Better Start។

Angelman syndrome (ជម្ងឺលូតលាស់យឺតផ្នែកប្រាជ្ញាស្មារតី)
Cerebral palsy (ជម្ងឺនៃការអន់ថយក្នុងការធ្វើចលនា និងរក្សាលំនឹងជំហរ និងឥរិយាបថ)
CHARGE syndrome (ជម្ងឺប៉ះពាល់ផ្នែកជាច្រើននៃរាងកាយដូចត្របកភ្នែក បេះដូង ស្ទះរន្ធច្រមុះពីកំណើត ត្រចៀក និងការលូតលាស់អន់ថយនៃសរីរាង្គបន្តពូជ)
Cornelia de Lange syndrome (ជម្ងឺប៉ះពាល់លើផ្ទៃមុខដូចជាមានធ្មេញ ភ្នែក ច្រមុះខុសធម្មតា និងការលូតលាស់ផ្នែកប្រាជ្ញាអន់ថយ)
Cri du Chat syndrome (ជម្ងឺនាំឲ្យខើច ឬរៀចមាត់ធ្វើឲ្យពិបាកលេប និងពិបាកជញ្ជក់ មានឥរិយាបថ សកម្មហួសហេតុ រំលោភឈ្លានពាន និងហៀរទឹកមាត់)
Down syndrome (ជម្ងឺធ្វើឲ្យការលូតលាស់ផ្នែករាងកាយ និងផ្នែកប្រាជ្ញាស្មារតីអន់ថយ)
Fragile X syndrome (ពិការភាពផ្នែកប្រាជ្ញាស្មារតី អាកប្បកិរិយា ការរៀនសូត្រ ផ្នែករាងកាយមានមុខវែង ត្រចៀកធំ ស្បែកទន់)
Fragile X syndrome (ជម្ងឺ Fragile X ដែលអាចផ្ទេរហ្សែនពិការភាពទៅឲ្យកូនចៅជំនាន់ក្រោយ រាប់បញ្ចូលទាំងកោសិកានៃមនុស្សតែម្នាក់ដែលមានចំនួនក្រូម៉ូសូមខុសគ្នា)
Kabuki syndrome (ជម្ងឺប៉ះពាល់រាងកាយច្រើនកន្លែងដូចជាមានចញ្ចើមកោងរោមភ្នែកវែង ត្របកភ្នែកវែង)
Prader-Willi syndrome (ជម្ងឺដែលមានខួរក្បាលមួយផ្នែកពុំអាចគ្រប់គ្រងការឆ្អែត និងការឃ្លាន ដែលនាំឲ្យបរិភោគច្រើនហួស ធ្វើឲ្យធាត់លើសកំរិត)
Smith-Magenis syndrome (ជម្ងឺប៉ះពាល់ដល់ការលូតលាស់ផ្នែកនៃរាងកាយ ការលូតលាស់ផ្នែកប្រាជ្ញាស្មារតី បញ្ហាផ្នែកអាកប្បកិរិយា)
Williams syndrome (ជម្ងឺប៉ះពាល់ដល់ការលូតលាស់របស់កុមារ ផ្នែករាងកាយ ផ្នែកយល់ដឹង)

# កំរិតយ៉ាងតិចបំផុតផ្នែកពិការភាពខាងក្រោមនឹងត្រូវអនុវត្ត:

**ភាពអន់ថយផ្នែកសោតវិញ្ញាណ**
កុមារនឹងមានសិទ្ធិទទួលបាន ប្រសិនបើគេស្តាប់ពុំឮដោយត្រចៀកទាំងសងខាងដែលសមស្រប តាមលក្ខណៈណាមួយនៃលក្ខណៈវិនិច្ឆ័យទាំងពីរដូចតទៅនេះ:

- ការស្តាប់ពុំឮជាអចិន្ត្រៃយ៍ដោយសារកំរិតសូរសម្លេងថយចុះ ឬការខូចក្រដាសត្រចៀក ខូចសរសៃប្រសាទដែលភ្ជាប់ត្រចៀកទៅខួរក្បាលដែលមានរលកសម្លេងចំនួន៤នៃការស្តាប់ពុំឮជាមធ្យម* នៃកំរិត 40dBHL ឬធំជាងនេះក្នុងត្រចៀកដែលឮបានល្អ។
- ជម្ងឺវិសាលគមន៍នៃរោគសរសៃប្រសាទនៃការស្តាប់ ត្រូវបានធ្វើរោគវិនិច្ឆ័យក្នុងត្រចៀកទាំងសងខាង

* រលកសម្លេងចំនួន៤នៃការស្តាប់ពុំឮជាមធ្យម ជាតំណាងកំរិតស្តាប់ឮយ៉ាងតិចបំផុតជាមធ្យមនៅរលកសម្លេង 500 Hz, 1000 Hz, 2000 Hz និង 4000 Hz។

**Microcephaly (ជម្ងឺក្បាលតូចខុសធម្មតាដោយការខកខានលូតលាស់នៃខួរក្បាល)**
ការធ្វើរោគវិនិច្ឆ័យនៃ microcephaly ផ្អែកលើបរិវេណជុំវិញក្បាលតិចជាងរង្វាស់បីភាគរយ និងកំរិតបំពេញមុខងារនៅត្រឹម ឬខាងក្រោម 2 standard deviations ខាងក្រោមមធ្យមភាគសម្រាប់អាយុតាមកម្រិតវាស់ស្ទង់នៃការលូតលាស់នៃគំនិតប្រាជ្ញាតាមបែប Griffiths ឬកម្រិតវាស់ស្ទង់នៃការលូតលាស់នៃកូនក្មេងតាមបែប Bayley។

**ភាពអន់ថយផ្នែកចក្ខុវិញ្ញាណ**
ដើម្បីមានសិទ្ធិទទួលបានកិច្ចបំរើរបស់ Better Start កំរិតតិចបំផុតនៃភាពអន់ថយផ្នែកចក្ខុវិញ្ញាណគឺត្រូវតិចជាង ឬស្មើនឹង 6/18 ឬមានតម្លៃស្មើគ្នានឹងទំហំមើលឃើញដែលបាត់បង់ក្នុងភ្នែកល្អប្រសើរដែលមានការកែតម្រូវ។

ល័ក្ខខ័ណ្ឌអនុវត្តចំពោះកូនក្មេងតូចខ្លាំង និងកូនក្មេងក្នុងស្ថានភាពដទៃខ្លះទៀតដែលប៉ះពាល់ដល់សមត្ថភាពរបស់គេ ដើម្បីធ្វើសហប្រតិបត្តិការក្នុងកំឡុងពេលធ្វើតេស្ត ដូច្នេះហើយគេពិបាកធ្វើឲ្យដឹងកំរិតជាក់លាក់នៃភាពអន់ថយ។ សូមនិយាយទៅកាន់ RIS ក្នុងតំបន់របស់លោកអ្នក។

**ភាពថ្លង់ និងខ្វាក់**
កូនក្មេងទាំងអស់ដែលរោគវិនិច្ឆ័យនៃភាពថ្លង់ និងខ្វាក់ត្រូវបានធ្វើឡើងជាមួយក្រុមអ្នកឯកទេសច្រើនផ្នែក មានរួមទាំងការវាយតម្លៃផ្នែករោគភ្នែក និងរោគត្រចៀកផងដែរ (ដូច្នេះការអនុវត្តន៍ចំពោះកំរិតយ៉ាងតិចបំផុតពុំជាការចាំបាច់ឡើយ) នឹងមានសិទ្ធិទទួលបានកិច្ចបំរើ។

57824 Better_Start_Brochure Khmer.indd 2
3/06/13 11:16 AM